# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និង ឧតុនិយម
ចូល លេខ: 4.7.23
ថ្ងៃទី 6.11.23 ម៉ោង
បញ្ជូន

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ : ៨៤ ប្រក.បក

អាជ្ញាធរទន្លេសាប
ចូល ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០២៣
ម៉ោង ៣:០០ ។
លេខ: ១៧៣ អ.ទ.ស/លេខ

# ប្រកាស

## ស្តីពី

## ការអនុញ្ញាតឱ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម

## ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៥៨ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សាក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងសំណើចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ របស់លោកជំទាវ **អូក ដារី**

## សម្រេច

**ប្រការ១.-**

អនុញ្ញាតឱ្យលោកជំទាវ **អូក ដារី** នាយក្រមការ ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ស្ថិតនៅក្រៅក្របខ័ណ្ឌដើមនៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីទៅបំពេញការងារជាទីប្រឹក្សាអាជ្ញាធរទន្លេសាបនៃក្រសួងធនធានទឹក និងឧតុនិយម រហូតដល់ចប់ភារកិច្ច។

**ប្រការ២.-**

ក្របខ័ណ្ឌលោកជំទាវ **អូក ដារី** ត្រូវបានរក្សាទុកនៅទីស្តីការគណៈរដ្ឋមន្ត្រី ដោយឡែកប្រាក់បៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ត្រូវផ្ទេរទៅក្រសួងធនធានទឹក និងឧតុនិយម។

**ប្រការ៣.-**

នៅពេលចប់ភារកិច្ច សាមីខ្លួនត្រូវដាក់ពាក្យសុំចូលបម្រើការងារ និងផ្ទេរប្រាក់បៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស មកទីស្ដីការគណៈរដ្ឋមន្ត្រីវិញ។

**ប្រការ៤.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៤ រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**កន្លែងទទួល ៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ

លេខ ៖ .....១៣៣០.........ចល.ធទខ
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ សុក្រ ១២រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២៣

**ត.ប.រដ្ឋមន្ត្រី**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល**

**ម៉េង ប៊ុគន្ធ**